# បច្ចេកទេសផលិតកូនត្រីប្រាធំ

# Manual for the Seed Production of Stripped Catfish, *Pangasius hypophthalmus*


រៀបរៀងដោយៈ

បណ្ឌិត ស៊ីរ៉ូ ហារ៉ា (Shiro Hara)   និងលោក រស់ ណារិន

ប្រែសម្រួលជាភាសាខ្មែរដោយៈ លោក អ៊ុច ឡុង់ និងលោក សំ ណារិទ្ធ

កែសម្រួលដោយៈ នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល



រក្សាសិទ្ធិដោយៈ នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម



ឆ្នាំ ២០១០

# មាតិកាអត្ថបទ

អារម្ភកថា.........................................................................................-ខ-
សេចក្ដីថ្លែងអំណរគុណ...............................................................................-ឃ-
១. ការគ្រប់គ្រងត្រីពូជ...............................................................................-១-
២. ការរៀបចំស្រះបំប៉នកូនត្រី.......................................................................-៣-
៣. ការបង្កាត់ភ្ញាស់ត្រីដោយសិប្បនិម្មិត...............................................................-៤-
ា៣.១ ការជ្រើសរើសត្រីពូជ.......................................................................-៤-
៣.២ ការចាក់អ័រម៉ូន...............................................................................-៥-
៣.៣ ការច្បូតពង និងការផ្សំកំណើត...........................................................-៧-
៤. ការភ្ញាស់ពងត្រី...................................................................................-១០-
៥. ការថែបំប៉នកូនត្រីមេ្យា...........................................................................-១៤-
៥.១ ការថែបំប៉នកូនត្រីនៅដំណាក់កាលដំបូង.................................................-១៤-
៥.២ ការថែបំប៉នកូនត្រីនៅដំណាក់កាលចុងក្រោយ...........................................-១៧-
៦. ការត្រួតពិនិត្យជំងឺ និងសត្វល្អិត...................................................................-១៨-
៧. ការប្រមូលផល និងដឹកជញ្ជូន...................................................................-២០-

# អារម្ភកថា

ត្រីប្រាធំ *(Pangasius hypophthalmus)* ជាប្រភេទត្រីមានដើមកំណើតនៅក្នុងទន្លេមេគង្គ ហើយធ្វើបំលាស់ទីទៅរស់នៅតាមដងទន្លេ បឹង និងអាងទឹកនានានៅក្នុងបណ្ដាប្រទេសតំបន់អាស៊ី។ ត្រីប្រាធំ *(P. hypophthalmus)* ជាត្រីមួយប្រភេទមានការពេញនិយមចូលចិត្តចិញ្ចឹមពីសំណាក់ប្រជាកសិករ អាស្រ័យដោយវាមានចរិតស៊ីចំណីចម្រុះ លូតលាស់លឿន ធន់នឹងជំងឺអាចរស់នៅបានក្នុងលក្ខខណ្ឌដែលមានបរិមាណអុកស៊ីហ្សែនរលាយក្នុងទឹកទាប ហើយអាចផលិតកូនពូជបាននៅតាមកសិដ្ឋាន និងមានតម្រូវការនៅលើទីផ្សារខ្ពស់។

នៅក្នុងប្រទេសកម្ពុជា ប្រភពកូនត្រីពូជប្រាធំនៅមានកម្រិតនៅឡើយ ដែលបានមកពីការផលិតរបស់ស្ថានីយ៍មួយចំនួនតែប៉ុណ្ណោះ ដូចនេះកូនត្រីប្រាធំ *(P. hypophthalmus)* ភាគច្រើនត្រូវបាននាំចូលមកពីប្រទេសជិតខាង។ កង្វះខាតនៃប្រភពកូនត្រីប្រាធំ សម្រាប់ចែកចាយលក់ជូនកសិករ គឺអាស្រ័យដោយមានការខ្វះខាតលើផ្នែកព័ត៌មាន និងបច្ចេកទេសផលិតកូនត្រីប្រាធំ *(P. hypophthalmus)*។

នៅឆ្នាំ ២០០៧ ការអភិវឌ្ឍន៍បច្ចេកទេសផលិតកូនត្រីប្រាធំ *(P. hypophthalmus)* បានចាប់ផ្ដើមដំណើរឡើងនៅក្នុងមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប នៅខេត្តព្រៃវែងដោយមានកិច្ចសហការគ្នារវាងរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) រហូតមកដល់ឆ្នាំ ២០១០។ ចាប់ពីឆ្នាំ ២០០៧ មកដល់បច្ចុប្បន្ននេះចំណេះដឹងបច្ចេកទេសចិញ្ចឹមត្រីប្រាធំ ការផ្សំចំណីត្រី ការប្រើប្រាស់អ័រម៉ូន ការរៀបចំស្រះ និងការថែបំប៉នកូនត្រីក្នុងស្រះត្រូវបានរៀបចំ កែប្រែឱ្យកាន់តែល្អប្រសើរឡើង ហើយចំពោះបច្ចេកទេសផលិតកូនត្រីពូជវិញក៏ត្រូវបានរៀបចំចង

ក្រុងជាឯកសារបច្ចេកទេសដែរ ។

ឯកសារនេះ បានធ្វើការបកស្រាយបង្ហាញជូនសំខាន់ទៅលើបច្ចេកទេសផលិតកូនត្រីប្រាធំ ដោយប្រើប្រាស់ត្រីមេពូជបានមកពីការចិញ្ចឹមថែបំប៉ននៅក្នុងស្រះ ។

យើងសង្ឃឹមថា ឯកសារនេះនឹងចូលរួមចំណែកធ្វើឱ្យប្រសើរឡើង ហើយអាចនឹងទទួលយក និងអនុវត្តបានក្នុងការផលិតពូជកូនត្រីប្រាធំ ដើម្បីជួយជំរុញការអភិវឌ្ឍវារីវប្បកម្មឱ្យកាន់តែរីកចម្រើនឡើងនៅក្នុងប្រទេសកម្ពុជា ។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមបណ្ឌិត **ណៅ ធួក** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលបានជួយជ្រោមជ្រែងលើកទឹកចិត្តក្នុងការសិក្សាស្រាវជ្រាវឱ្យមានដំណើរការល្អ និងទទួលបានជោគជ័យ ។

យើងខ្ញុំក៏ សូមថ្លែងអំណរគុណផងដែរ ចំពោះមន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម និងលោក **ខ៊ាន់ ហេង** ប្រធាន និងលោក **សំ ណារិទ្ធ** អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប រួមទាំងមន្ត្រីទាំងអស់ដែលបានចូលរួមក្នុងសកម្មភាពការងារគម្រោង និងការសិក្សាស្រាវជ្រាវនេះ ព្រមទាំងលោក **Satoshi Chikami** លោក **Yoshitetsu Nukiyama** ប្រធានទីប្រឹក្សាគម្រោងបង្កើនផលិតភាព និងផ្សព្វផ្សាយវារីវប្បកម្មទឹកសាប (FAIEX Project/JICA) ដែលបានដឹកនាំអនុវត្តគម្រោងប្រកបដោយភាពរលូន និងប្រកបដោយជោគជ័យ ។

ឯកសារស្តីពីបច្ចេកទេសផលិតពូជកូនត្រីប្រាធំនេះ ត្រូវបានរៀបចំចងក្រងលេចចេញជារូបរាងឡើង អាស្រ័យដោយមានការជួយឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុរបស់អង្គការចៃកា (JICA) ។

ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១០

បណ្ឌិត **ស៊ីរ៉ូ ហារ៉ា (Shiro Hara)**

មន្ត្រីបច្ចេកទេសស្ម័គ្រចិត្តជាន់ខ្ពស់

អង្គការចៃកា (JICA)

## ១. ការគ្រប់គ្រងត្រីពូជ

ដើម្បីសម្រេចបានជោគជ័យក្នុងការផលិតពូជកូនត្រីប្រាធំ *(P. hypophthalmus)* នោះយើងត្រូវធ្វើការគ្រប់គ្រងស្រះត្រីមេពូជឱ្យបានល្អ ជាពិសេសគ្រប់គ្រងការផ្តល់ចំណីដែលជាចំណុចសំខាន់ ដើម្បីធ្វើឱ្យការបន្តពូជមានការលូតលាស់ និងគុណភាពល្អនៅក្នុងរដូវកាលបង្កាត់ភ្ញាស់ ចាប់ពីខែ មេសា ដល់ ខែ សីហា។

ជាទូទៅ មេពូជត្រីប្រាធំ *(P. hypophthalmus)* មានទំហំធំជាងត្រីឈ្មោល។ នៅ ឆ្នាំ ២០០៩ ក្រុមអ្នកបច្ចេកទេសយើងខ្ញុំបានធ្វើការថ្លឹងទម្ងន់ត្រីមេពូជ និងបានកត់ត្រាទិន្នន័យទំហំត្រីមេពូជញីជាមធ្យមទម្ងន់ ៧,១ គីឡូក្រាម/ក្បាល និងឈ្មោលទម្ងន់ ៦,១ គីឡូក្រាម/ក្បាល។ នៅក្នុងចំណោមត្រីមេពូជទាំងអស់នោះ មានត្រីមេពូជដែលអាយុតិចបំផុត ២ ឆ្នាំ អាចបន្តពូជពងកូនបានដែលក្នុងនោះរាប់បញ្ចូលទាំងញី និងឈ្មោល (រូបភាពទី ១)។



រូបភាពទី១: ត្រីមេពូជអាយុ ២ ឆ្នាំ



រូបភាពទី២: ស្រះមេពូជ ៨០០ ម៉ែត្រការ៉េ

ត្រីមេពូជទាំងអស់ដែលបានរៀបរាប់ខាងលើត្រូវបានធ្វើការថែបំប៉ននៅក្នុងស្រះដែលមានជម្រៅ ១,៥ ម៉ែត្រ ឬ ជ្រៅជាងនេះ ដោយដាក់បំប៉ននូវកម្រិតដង់ស៊ីតេ ០,៥ គីឡូក្រាមត្រីមេពូជក្នុងម៉ែត្រការ៉េស្រះ (រូបភាពទី ២) ហើយធ្វើការផ្លាស់ប្តូរទឹកក្នុងស្រះជាប្រចាំនូវកម្រិត ១ ភាគ ៣ នៃបរិមាណទឹកក្នុងស្រះរៀងរាល់ ១៥ ថ្ងៃម្តង។